...យកឈាមមកជាត់គំនូរ?

អូយ!.....

«បើអ្នកណាម្នាក់ដែលមិនមែនជាវិចិត្រករនឹងមិនធ្លាប់បានដឹងរឿងអស់នេះ និយាយអំពីឈាមនៅលើផ្ទាំងគំនូរ ពួកគេអាចមានអារម្មណ៍ថា ខ្លាចឬខ្ពើមមិនខាន! ប៉ុន្តែ....មានការអះអាង វិចិត្រករល្បីៗជាច្រើនលើលោកបានបរិច្ចាគឈាមរបស់ពួកគេផ្ទាល់ដើម្បីឱ្យគំនូរមានពណ៌រំលេចពិសេសហើយកាន់តែយូរឆ្នាំកាន់តែដាមចាស់ និងកាន់ល្អ!»

គ្រប់គ្នាកំពុងស្តាប់យ៉ាងជក់ចិត្ត។ ក្នុងចំណោមអ្នកស្តាប់ភាគច្រើនជានិស្សិតនិងជាងគំនូរថ្មីៗវ័យក្មេងជំនាន់ក្រោយ ឯអ្នកនិយាយនេះគាត់ឈ្មោះជា បណ្ឌិត គ្រូផ្នែកវិចិត្រកម្មដ៏ល្បី មានស្នាដៃគំនូរដែលមានតម្លៃច្រើន ហើយគាត់ក៏ជាម្ចាស់កម្មវិធីពិព័រណ៍«គំនូរទឹកប្រៃ»ដ៏ជោគជ័យមួយនេះដែរ។

«លោកគ្រូមានដែលសាកទេទាន?!»

ខ្ញុំរកសួរហើយតែនាងសួរមុនខ្ញុំ។ ក្រមុំម្នាក់នេះមិនមែនជាអ្នកកាសែតដូចខ្ញុំទេ នាងប្រហែលជាអ្នកដែលមកចូលរួមដាក់ស្នាដៃពិព័រណ៍ដែរហើយ ព្រោះឃើញរត់ចុះឡើងពេញហ្នឹងមួយព្រឹកធំ។

«ធ្លាប់បាទ! គំនូរមួយ ខ្ញុំលក់ទៅអារ៉ាប់ហើយ! ឈ្មោះថាព្រះអាទិត្យក្រហម រួចរាល់នៅឆ្នាំ១៩៨៣! យូរហើយ!»

«វាជះក្លិនទេ ក្រោយពេលគូរលោកគ្រូ?!»

«អត់ផង! ធម្មតា! គ្មានក្លិន គ្មានអីទាំងអស់ដូចថ្នាំដែរ តែវាស្អាតជាងរលោង និងចាស់ជាងពណ៌ថ្នាំ!»

ងឹត!

ស្នូរជាន់ហ្វ្រាំងមួយខ្សែយ៉ាងវែង បានញ៉ាំងឱ្យគ្រប់គ្នាត្រូវរន្ធត់ញាប់ញ័របែរក្រោយសម្លឹងថ្នល់មួយនៅពីមុខកន្លែងតាំងពព័រណ៍នេះ ក៏ជាពេលនារីរូបស្អាតម្នាក់រហ័សសៃនរហ័ស នាងស្ទុះទៅជួយទាញលោកតាចំណាស់កំពុងឆ្លងផ្លូវដួលច្រងាប់ច្រងិលមកក្បែរចិញ្ចើមថ្នល់គេចចេញពីសន្ទុះឡានផ្តាច់ព្រលឹង។

រថយន្តដ៏សែនលឿនមួយនោះអូសច្រើនសិបម៉ែត្រទៀត ទម្រាំទប់ជំហរបានមកវិញ។ សំណាងហើយ គ្មានអ្វីពាំងពីមុខ......

«ពួកតាក់ស៊ីមិនគោរពច្បាប់ចរាចរណ៍ដដែល!»

ពួកអ្នកដែលកំពុងពិភាក្សារឿងគំនូរបាននាំគ្នាដូរប្រធានបទហើយ។

«ម្នាក់ស្រីនោះលឿនមែនជួយអ៊ំនោះបាន!»

«ដូចជាតាន់តរុណី?»

«ត្រូវហើយ តាន់តរុណី! អស្ចារ្យណាស់ វិចិត្រករល្បីក៏មកដែរ! ហើយមកជួយជីវិតមនុស្សបានម្នាក់ទៀត?»

«មានហើយស្អាតហើយពូកែថែមទាំងចិត្តល្អទៀត!»

គ្រប់គ្នាបំបែរទៅទិសដៅទៅរកនារីដែលបានដើរតួជា Superhero អម្បាញ់មិញ។ នាងកំពុងហុចប្រេងកូឡាឱ្យទៅបុរសចំណាស់ ដែលអង្គុយផ្ទាល់ដោយរន្ធត់លើចិញ្ចើមថ្នល់ព្រោះទើបរួចជីវិតពីមរណាតែហោង។ មើលពីនេះទៅក៏ខ្ញុំអាចវាយស្មានបានថា នាងប្រហែលជាមកចូលរួមកម្មវិធីនេះដែរ ព្រោះនៅនឹងដៃម្ខាងទៀតនាងកាន់មកតាមនូវសម្ពាយដាក់សម្ភារៈគំនូរនិងលៀនដងជក់មួយចំនួនមកក្រៅ។

សភាពរបស់នាង អ្នកណាក៏គិតថាអស្ចារ្យដែរ។

សង្គ្រោះចប់ ស្រីស្អាតបោះជំហានស្មើផេងមិនស្លុតរន្ធត់ឬរំភើបអ្វី ធ្វើមុខញញឹមហើយដើរហួសទៅកាន់សាលពិព័រណ៍ធំ។

រថយន្តតាក់ស៊ីរ៉ឺយ៉េរគេចបាត់ស្រមោលហើយខ្លាចក្រែងសមត្ថកិច្ចមកទាន់នឹងបានឃាត់ពិន័យឬធ្វើការប្រដៅអប់រំច្បាប់។

«ជម្រាបសួរបាទ! ខ្ញុំឈ្មោះពុទ្ធា ទាន!»

«អូ! លើកដៃថ្វាយព្រះក្នួយ! មកដល់ហើយ?!»

«បាទ ខ្ញុំមកជួបលោកសាស្ត្រាចារ្យ ជា បណ្ឌិត!»

«ខ្ញុំហ្នឹងហើយ! អរគុណទៅដល់លោកចាងហ្វាងកាសែតផង ដែលបានចាត់សហការីចុះមកចងក្រងព័ត៌មាននិងឯកសារអំពីពិព័រណ៍នេះ តោះៗអញ្ជើញមកតាមខ្ញុំសិន នឹងបានជូនរកកន្លែងសម្រាក!»

«បាទ! សូមអរគុណលោកគ្រូណាស់ ប៉ុន្តែ....»

ព្រោះគាត់ដើរលឿនរ៉ុយទៅ ម៉្លោះហើយខ្ញុំត្រូវខំប្រឹងនិយាយទាំងជើងត្រដរញាប់ស្មេរតាមពីក្រោយគាត់...វិចិត្រករម្តេចក៏រហ័សៗម្ល៉េះហ្ន៎ យើងជាអ្នកកាសែតផង គួរតែសុំចាញ់?

«ចង់និយាយអំពីពេលវេលាលោកក្មួយធ្វើសម្ភាសន៍?»

«បាទទាន!»

«នៅទេ! សម្រាកសិន! ទើបមកដល់ រកបាយទឹក អាហារសមុទ្រសម្រន់សិន! ល្ងាចត្រជាក់ចេញដើរមើលមួយត្រួសសិនទៅនឹងអាលមានគំនិតដាក់សំណួរច្រើន!»

ជាអ្នកសារព័ត៌មានស្ទើរបទពិសោធម្នាក់ ខ្ញុំនៅតែអាចកាត់យល់បានថា គាត់ពិតជាមនុស្សមានដំបូន្មានល្អនិងមានការចាត់ចែងល្អិតល្អន់ផង សក្តិសមណាស់នឹងកេរ្តិ៍ឈ្មោះជាអ្នករៀបចំពិព័រណ៍សិល្បៈដ៏ជោគជ័យម្នាក់។

ភ្លាមនោះ...នារី Superhero បង្ហាញខ្លួនក្បែរសួនផ្កា នាងកំពុងតែបែរខ្នងរៀបចំផ្ទាំងគំនូរមួយ ទៅលើជញ្ជាំងពិព័រណ៍។ ខ្ញុំចាប់អារម្មណ៍លើនាងមិនទាន់បាត់នៅឡើយទេ។ បន្ទាប់ពីលោកសាស្ត្រាចារ្យខ្ញុំប្រាកដជាសម្ភាសន៍នាងហើយ! គិតផងខ្ញុំតាមមើលនារីសឹងរៀចទាំងខ្លួនដែលកំពុងដើរ។

នាងពិតជាទាក់ចិត្តណាស់...

«មនុស្សស្រីម្នាក់...ម្នាក់...ម្នាក់នោះ...»

សាស្ត្រាចារ្យងាកមកពិនិត្យតាមចង្អុលដៃខ្ញុំ។

«...ខ្ញុំក៏ចង់សុំសម្ភាសគាត់ដែរ...បានទេទាន?!»

អ្វីមួយផ្សេងបានកើតឡើងហាក់ចម្លែកនៅក្នុងកែវភ្នែករបស់អ៊ំសាស្ត្រាចារ្យ ជា បណ្ឌិត។ គាត់កែទឹកមុខមកវិញរួចតបនឹងសំណួរខ្ញុំ៖

«តាន់ តរុណី?»

«បាទទាន!» អូយឈ្មោះសែនពីរោះ ខ្ញុំលបគិតទាំងលេបទឹកមាត់ចង់ជួបផ្ទាល់ ប៉ងនឹងបានជជែកតទល់ស្គាល់សូរសៀងថាពីរោះកម្រិតណា?

«អឺ..រឿងសម្ភាសន៍ ចាំខ្ញុំជួយសួរឲ្យ! តែមិនសន្យាទេ មិនដឹងដែរថានាងព្រមឬក៏យ៉ាងម៉េច!»

មើលទៅគាត់មានលក្ខណៈរុញរាស្រេចហើយ គឺសភាពដូចជាអត់ចង់ឲ្យខ្ញុំបានសម្ភាសន៍នាងទេ។

គាត់ហួងហែងធ្វើអ្វីទៅ?

ឬនាងឫកខ្ពស់ពេក គាត់ដឹងស្រេចថា នាងនឹងមិនជួបអ្នកសារព័ត៌មិនល្បីដូចជាខ្ញុំ?

សាស្ត្រាចារ្យទំនងឃើញទឹកមុខខ្ញុំ គាត់បែរមកពន្យល់វិញដែរថា៖

«គាត់គឺជាភ្ញៀវកិត្តិយសរបស់យើង! ខ្លាចតែថាអ៊ំសម្រេចចិត្តម្នាក់ឯង ប៉ះពាល់ដល់អារម្មណ៍គាត់! ត្រូវសួរនាំចិត្តគាត់ដែរព្រោះយើងអត់បានជូនដំណឹងមុន! អូខេដល់ហើយនេះ! បត់ទៅស្តាំបន្តិច បន្ទប់ចុងគេហ្នឹងជាបន្ទប់សម្រាករបស់ក្មួយ! ហើយនេះសោ!»

គាត់លូកយកសំណុំសោរប្រមាណដប់-ម្ភៃចេញមកពីកាបូប ហើយរាវដកកូនតែមួយមកឱ្យខ្ញុំ។

ខ្ញុំទទួលបម្រុងសំពះលាគាត់ត្រឹមណោះ ស្រាប់តែគាត់ងាកមកបន្ថែម៖

«...ប៉ុន្តែពេលលោកក្មួយចង់ដើរផ្លូវកាត់ទៅកាន់សាលពិព័រណ៍ធំវិញ អាចដើរតាមផ្លូវតូចខាងមុខនោះក៏បាន! ប៉ុន្តែពេលយប់កុំប្រថុយអី!»

«មិនមានសុវត្ថិភាព?!»

«ព្រៃដុះច្រើនបន្តិច អមតាមផ្លូវ ណាមួយអត់អំពូលភ្លើងសូឡាគ្រប់ផង ខ្លាចក្រែងមានសត្វលូនឆ្លងកាត់អីគ្រាន់តែបង្ការទេ! មិនធ្លាប់មានហេតុភេទនៅឡើយ!»

ខ្ញុំលំឱនកាយហើយគិតថា គាត់ប្រហែលជាសំដៅទៅលើសត្វពស់ឬក៏សត្វអីមានពិស អាចយាយីយើង។

«ខ្ញុំកំពុងតែដាក់ស្នើសុំអំពូលសូឡា ដើម្បីរៀបចំផ្លូវលំនេះមួយទៀតឲ្យភ្ញៀវដែលមកសម្រាកនៅភូមិក្រោយហ្នឹងគាត់អាចមកកាន់សាលពិព័រណ៍ធំដោយមិនបាច់ចូលតាមខ្លោងមុខ! គឺដើរឆាប់បានដល់ជាង យើងដើរតាមឆ្នេរចាស់!»

«បាទ!»

«អ៊ីចឹងសម្រាកសិនទៅលោកក្មួយ!»

«ជម្រាបលាទាន!»

គាត់ចាកចេញទៅដោយកាយវិការរួសរាន់ ចំណែកខ្ញុំចាក់សោចូលមកក្នុងបន្ទប់។ នាឡិកាលើជញ្ជាំងបង្ហាញថា ម៉ោង៤ល្ងាចហើយ។ ទីនេះមើលទៅតូចល្មម ប៉ុន្តែរៀបចំបានគួរសម គ្មានធូលីដី ក្រាលកម្រាលបានស្អាតនិងមានទឹកសុទ្ធ២ដបផ្លែក្រូចមួយចំនួនលើតុផង។

តុសម្រាប់សរសេរនេះ ដាក់ក្បែរបង្អួចដែលអាចសម្លឹងទៅឃើញសមុទ្រគ្រាន់តែខ្ញុំមិនដឹងថាជាឆ្នេរអ្វីព្រោះមុនទាន់បានចេញដើរប្រទ្រុយ។ ព្រះសូរិយាហៀបអស្តង្គតពិតជាផូរផង់ពណ៌មាស...

គ្រប់យ៉ាងសក្តិសមជាមួយអ្នកសារព័ត៌មានផ្នែកសិល្បៈដូចខ្ញុំណាស់ហើយនិងបានលំហែផង បានសរសេរផ្ទង់អារម្មណ៍ល្អផង។

ប៉ុន្តែអារម្មណ៍របស់ខ្ញុំភ្លាមនោះ ក៏នឹកឃើញទៅដល់មនុស្សស្រីរហ័សរហួនម្នាក់ តាន់ តរុណី។

អារម្មណ៍ប្រុសកម្លោះនឹកដល់ស្រីក្រមុំជារឿងធម្មតា ចំណែកនាងវិញ ខ្ញុំជឿថាមិនមែនមានតែម្នាក់ខ្ញុំទេដែលកំពុងនឹកដល់នាង។ ខ្ញុំប្រញាប់លើក Laptop មកដាក់លើកូនតុនេះហើយភ្ជាប់អ៊ីនធឺណិតនឹងអាលប្រញាប់បានស្រាវជ្រាវអំពីនាងលើបណ្តាញសង្គម។

តរុណីដែលមានរាងខ្ពស់ស្រឡះ មានចង្កេះរាងរាវ ទីបំផុតខ្ញុំរកឃើញនាងមែន។ នាងមាន Follower ច្រើនទាំងនៅលើហ្វេសប៊ុកនិងតេលេក្រាម។

រូបថតច្រត់ចង្កេះដៃកាន់ជក់ពិតជារូបស្អាតបំផុតរបស់នាង។

នាងល្បីឈ្មោះគួរសមក្នុងពិភពវិចិត្រកម្ម តែខ្ញុំវិញ ខ្ញុំទើបតែស្គាល់នាងពេលនេះ ដោយសារខ្ញុំទើបនឹងចាប់ការងារសិល្បៈគំនូរជាដំបូងទេ ចំណែកពិព័រណ៍ទឹកប្រៃនេះទៀតសោតក៏ជា eventទីមួយដែលមេខ្ញុំប្រើឱ្យមក Cover សរសេរអត្ថបទនិងធ្វើឯកសារ។

ចុងក្រោយ ខ្ញុំថយមកប្រះលក់មួយភាំង.....

សន្ទឹកអ្វីមួយបានដាស់ខ្ញុំឲ្យបើកភ្នែកខ្វាកមកវិញឥតព្រាងទុក....សម្រិបជើងមនុស្សលាន់មកស្រាលៗ។ ខ្ញុំរំពៃត្រចៀកស្តាប់....ពិតជាមានអ្នកណាប្រឹងដើរស្រាលៗលបៗក្បែរៗនេះ។

ខ្ញុំងាកសម្លឹងទៅបង្អួចដែលជាប្រភពសូរសំឡេង....មេឃខាងក្រៅងងឹតហើយ?

ហេតុអ្វីដេកដូចមិនធ្លាប់បានដេក?

ម៉ោងប៉ុន្មានហើយអ៊ើយ...កម្មវិធីជប់លៀងបើកពិព័រណ៍ចាប់ផ្តើមបាត់ហើយដឹង? ខ្ញុំគិតទាំងស្ទុះក្រោកឡើងមករៀបរយខោអាវ...រវៃភ្នែកប្រុងរកទាញសម្ភារៈទូរសព្ទនិងកុំព្យូទ័រចាកចេញ...

សក់មនុស្សស្រីបង្ហើរតិចៗអន្លាយនៅក្រៅបង្អួច...ក្រោមអំពូលខៀវព្រឹល ដៃខ្ញុំហាក់ព្រឺនិងចាប់ផ្តើមបះរោម...

«អ្នកណានៅក្រៅ?»

ខ្ញុំហាមាត់សួរញ៉េរៗ ធ្វើឱ្យសរសៃសក់វែងដែលរសាត់មិនឃើញមុខម្ចាស់មុននេះ បាត់ទៅវឹងដូចមានគេកន្ត្រាក់ទាញ។

លេងសើចមិនសមទេថ្មើរណេះ!

ខ្ញុំស្ទុះរត់ទៅបង្អួចភ្លាមចង់ដឹងថាអ្នកណា។

ភ្ញាក់ដូចគេកន្ត្រាក់...

«តាន់ តរុណី?!»

ខ្ញុំហៅគេទាំងឈ្មោះទាំងត្រកូល ព្រោះគេជានារីដែលខ្ញុំបានចាប់អារម្មណ៍កាលពីល្ងាច ពេលនេះកំពុងមានវត្តមានឈរខាងក្រៅបង្អួចហើយលិបលទៀត។ ឆ្ងល់?

នាងបើកភ្នែកធំៗសម្លឹងមកខ្ញុំវិញដោយសេចក្តីភ្ញាក់ផ្អើល។ ពិនិត្យសភាពរបស់នាងក្នុងពេលនេះសមតែកំពុងប្រដេញតាមអ្វីមួយ ...?

ខ្ញុំចាកចោលបង្អួចនេះជាបន្ទាន់ដោយចេញតាមទ្វារបន្ទប់មករកនាង....នាងពិតជាមិនបានទៅណាមែននៅឈរទីនោះដដែលបានជាខ្ញុំដាច់ចិត្តសួរឡើងថា៖

«មានការអី? ខ្ញុំជួយបានអត់?!»

«មានឃើញមនុស្សប្រុសម្នាក់រត់កាត់ហ្នឹងទេ!»

ខ្ញុំភ្លឹក!

មិនមែនភ្លឹកជាមួយពាក្យមនុស្សប្រុសរត់ទេ តែសំនៀងដែលនាងនិយាយឡើង។ សម្រស់សំឡេងនិងមនុស្ស ពិតមិនល្អៀងគ្នាមែន។ លង់ហើយ!

ឃើញខ្ញុំគ្រវីក្បាល នាងខ្សឹបខ្សៀវដោយឱនមកក្បែរខ្ញុំ៖

«ពូឯងសម្រាន?»

ខ្ញុំមិនចាស់ឬទុំរហូតដល់ត្រូវនាងហៅថាពូទេ! ខ្ញុំតវ៉ា៖

«ខ្ញុំឈ្មោះពុទ្ធា! ហៅឈ្មោះក៏បាន!»

«ខ្ញុំតរុណី!»

«ខ្ញុំស្គាល់ហើយ វិចិត្រករគំនូរលេខមួយ!»

នាងភ្លឹកនឹងសម្ដីខ្ញុំដែលចាត់ថ្នាក់នាងថា«លេខមួយ» រួចសើចខឹកៗ!

«ខ្ញុំមកពីភ្នំពេញ មកCoverព័ត៌មានពិព័រណ៍នេះ»

គឺខ្ញុំចង់ប្រាប់គេថា យើងជាអ្នកចម្ងាយ គួរតែរាប់អានគ្នា គ្រាន់បានជា«គ្នា»។ នេះជាឱកាសមិនបានគិតរំពឹងមួយសម្រាប់កម្លោះកំព្រាបេះដូងដូចខ្ញុំ។ ទោះណាជាគេខ្ពស់ហួសហត្ថា តែខ្ញុំនឹងចាប់ឱកាសជានិច្ចឱ្យតែមាន។

«បានស្គាល់អ្នកកាសែតទៀតសំណាងមែន! ខ្ញុំទើបតែមកដល់បានមួយយប់ដែរហ្នឹង» នារីរូបនេះថាមកកាន់ខ្ញុំវិញទាំងសើចរាក់ទាក់។

ខ្ញុំភ្លឹកទៀតហើយពេលដែលបាននាងស្និទ្ធនឹងខ្ញុំជាងកាលធ្លាប់រំពឹងទុក។ ក្រោយពីបានជជែកជាមួយលោកសាស្ត្រាចារ្យជាបណ្ឌិត ខ្ញុំធ្លាប់យល់ខុសថាគេជាស្រីស្អាតនិងពូកែ អាចជាយុវនារីទេពកោសល្យដែលឆ្មើងកន្ទ្រើង មិនងាយនឹងផ្ដល់សម្ភាសន៍ ព្រោះនាងកំពុង«ឡូយខ្លាំង» តែនេះអត់ទេ នាងរួសរាយណាស់។

«ខ្ញុំឃើញប្រុសម្នាក់ចម្លែកណាស់ គេប្រលាក់ឈាមរបួសពេញខ្លួនរត់គេចខ្លួនកាត់តាមរបៀងនេះ!»

នាងចង្អុលទៅផ្លូវលំតូច ងងឹតស្លុប ហើយនិយាយខ្សឹបតិចៗជាមួយខ្ញុំដោយប្ដូរទឹកមុខជាឆ្ងល់និងសង្ស័យលើអ្វីមួយ។

«ខ្ញុំអត់ឮអីទេ!»

ខ្ញុំតបដោយរេសម្លឹងទៅទិសដៅដែលនាងកំពុងតែចង្អុលរួចបញ្ជាក់ទៀត....៖

«មុននេះ ខ្ញុំកំពុងលក់មួយភាំង! គេក៏សម្ដែងល្ខោនអ្វីមានតួលាបខ្លួនលាបមុខទេដឹង?»

«មានល្ខោនដែរ?!»

នាងសួរវិញ ខ្ញុំក៏មិនដឹងដែរ មានតែតបតាមត្រង់៖

«អត់...អត់ទេ! អត់ដឹងច្បាស់ទេខ្ញុំចេះតែថាទៅ ចុះគ្រែងមិញថា ឃើញមនុស្សប្រលាក់ឈាម? មានមនុស្សប្រឡាក់ឈាមរបួសមកពីណាមក? មានតែគេតួលេងល្ខោនដឹង? និយាយអ៊ីចឹងកម្មវិធីនៅសាលធំគេផ្តើមឬនៅ?!»

នាងមិនឆ្លើយនឹងសំណួរខ្ញុំបែរជាលូកមកទាញកដៃខ្ញុំទៅជ្រុងងងឹតហើយខ្សឹបៈ

«កន្លែងនេះមិនស្រួលទេ! ខ្ញុំឃើញមនុស្សប្រុសម្នាក់ប្រឡាក់ឈាមពេញខ្លួនមែនណា! គាត់ដើរកាត់បន្ទប់ខ្ញុំ ខ្ញុំរត់ចេញមកតាមមើល ក៏មកមិនទាន់តែឃើញគាត់រត់តាមណោះមកហើយចូលទៅផ្លូវងងឹតនោះ!»

ប្រធានបទ មនុស្សប្រុសប្រឡាក់ឈាមពេញខ្លួនមិនមែនរឿងល្អប៉ុន្មានទេសម្រាប់ពេលនេះ។

«មែនអត់? អាចថាព្រឹលភ្នែក?»

ខ្ញុំសួរបញ្ជាក់តែនាងធ្វើគ្រលួងៗមិនចុះញ៉មមិនសង្ស័យលើភ្នែកខ្លួននាងទេ។ វិចិត្រករចាប់ផ្តើមប្រាប់ខ្ញុំថាៈ

«ខ្ញុំក៏ជាអ្នកចូលរួមពិព័រណ៍គំនូរនេះដែរ តែក្រុមគំនូរស្រីៗគេឱ្យសម្រាកនៅសណ្ឋាគារមួយទៀត នៅជិតនេះដែរ គេថាសណ្ឋាគារប៉ុន្តែខ្ញុំមើលទៅដូចជាផ្ទះសំណាក់មានបន្ទប់ស៊ុបទ្រុបព័ទ្ធដោយព្រៃ! លោកគ្រូ ជា បណ្ឌិតហាមថា ពេលយប់មិនគួរដើរ ព្រោះអាចមានសត្វលូនកាត់នៅឡើយ!»

«ខ្ញុំក៏ដឹងដែរ ប៉ុន្តែសត្វអស់ហ្នឹង ពេលឃើញភ្លើងវាខ្លាចខ្លាំងណាស់ មានពិលធំៗទេ!!»

«អូខេចាំរកទិញ ប៉ុន្តែខ្ញុំសួររឿងមួយ! ពុទ្ធាឯងគេងម៉េចដែរម្តុំនេះ?!»

«គ្មានរឿងអីទាំងអស់! លក់ស្រួលណាស់ ប្រះភ្លាម រឹង!»

នាងស្រពោនមិនមាត់ដូចកំពុងតែត្រិះគិតទៅដល់រឿងអ្វីមួយចង់និយាយខ្លះចង់លាក់ខ្លះៈ

«ខ្ញុំវិញ!...និយាយទៅ ពេញមួយយប់មិញ ខ្ញុំគេងបានតិចណាស់! តិចបំផុតហើយ!»

«មានរឿងអីទៅ? ប្លែកកន្លែងមិនទម្លាប់ ឬមួយបន្ទប់គ្រែមិនស្អាត?!»

«ទេ! តែឮសូរមនុស្សប្រុសស្រែកថ្ងូរ! ឮរហូត....»

«ថាម៉េច?»

«មិនមែនជាការបំភ័យទេណ៎ា ខ្ញុំនិយាយមែនណ៎ាពុទ្ធា! ខ្ញុំឮសូរមនុស្សស្រែកថ្ងូរដោយឈឺចាប់ ហើយរកប្រភពមិនឃើញ ខ្ញុំឆ្ងល់ដល់ឥឡូវ ល្ងាចនេះទៀតព្រលប់ៗកំពុងអង្គុយលាតគំនូរមើល ក៏ឃើញមនុស្សប្រុសដើរកាត់បន្ទប់! តែមួយប៉ប្រិចភ្នែក ខ្ញុំឃើញខ្លួនគេប្រឡាក់ឈាមជោក ហើយចេញមករកស្ទូរនាំ ក៏តាមមិនទាន់!»

(នៅមានត)